World Health Organization
Western Pacific Region

# កម្ពុជា

## របាយការណ៍ស្តីពីស្ថានភាពជំងឺកូវីដ-១៩ លេខ#៨៩

របាយការណ៍គិតត្រឹមថ្ងៃទី ១៥ ខែសីហា ឆ្នាំ២០២២ ម៉ោង១០:00នាទីព្រឹក

## ស្ថានការណ៍សង្ខេបសំខាន់ៗ (ថ្ងៃទី១១ កក្កដា ដល់ថ្ងៃ ១៤ សីហា ឆ្នាំ២០២២)*

- ករណីវិជ្ជមានវីរុសកូវីដ-១៩ថ្មី បញ្ជាក់ដោយ PCR សរុបចំនួន ៩០២ ត្រូវបានរាយការណ៍នៅកម្ពុជានៅចន្លោះពេលពីថ្ងៃទី ១១ ខែកក្កដា ដល់ថ្ងៃទី ១៤ខែសីហា។ ករណីទាំងអស់នេះ ជាករណីឆ្លងក្នុងសហគមន៍។
- គិតត្រឹមថ្ងៃទី ១៥ ខែសីហា ឆ្នាំ២០២២ ករណីសរុបទាំងអស់ចំនួន ១៣៧.៣០០ ត្រូវបានបញ្ជាក់ថាជាករណីវិជ្ជមានវីរុសកូវីដ-១៩ និងករណីស្លាប់ចំនួន ៣.០៥៦ ត្រូវបានរាយការណ៍ដោយរាជរដ្ឋាភិបាលកម្ពុជាចាប់តាំងពីថ្ងៃទី ២៧ ខែមករា ឆ្នាំ២០២០មក។ ក្នុងចំណោមនោះ ១៣៣.៩៨២ករណីបានជាសះស្បើយ។
- គិតត្រឹមថ្ងៃទី ១៥ ខែសីហា ឆ្នាំ២០២២ តេស្តសរុបចំនួន ២.៦៥០.៦៩១ ត្រូវបានធ្វើដោយប្រើម៉ាស៊ីនតេស្តមន្ទីរពិសោធន៍ (RT-PCR) នៅកម្ពុជា។ រយៈពេលពីថ្ងៃទី ១១ ខែកក្កដា ដល់ថ្ងៃទី ១៤ ខែសីហា បានធ្វើតេស្តចំនួន ១៤.៧០៨ រកវីរុសកូវីដ-១៩ ដោយប្រើបច្ចេកវិទ្យាធ្វើតេស្តប្រើម៉ាស៊ីននៅមន្ទីរពិសោធន៍ (Reverse-Transcriptase Polymerase Chain Reaction, RT-PCR) ។
- គិតត្រឹមថ្ងៃទី ១៩ ខែសីហា ឆ្នាំ២០២២នេះ វ៉ាក់សាំងកូវីដ-១៩ ចំនួន ៤៤លានដូសត្រូវបានចាក់ជូនដល់ក្រុមប្រជាជនដែលមានសិទ្ធិទទួលបានវ៉ាក់សាំងអាយុចាប់៣ឆ្នាំឡើង។ ៩០,៥ភាគរយនៃចំនួនប្រជាជនសរុបទទួលបានវ៉ាក់សាំង២ដូស ហើយចំនួន ៦២,១ ភាគរយទទួលបានវ៉ាក់សាំងដូសជំរុញយ៉ាងហោចណាស់មួយដូស។
- កម្ពុជាបន្តមានករណីឆ្លងថ្មី និងការឆ្លងជាចង្កោមបន្តិចបន្តួច។ ទោះជាយ៉ាងណាក៏ដោយ មានសញ្ញាបង្ហាញពីការកើនឡើងនូវការប្រើប្រាស់ប្រព័ន្ធថែទាំសុខាភិបាល ឬក៏កំណើនបន្ទុកលើប្រព័ន្ធសុខាភិបាលនោះទេ។ ចាប់តាំងពីថ្ងៃទី ២០ ខែមេសា ឆ្នាំ២០២២មក មិនមានករណីស្លាប់ត្រូវបានរាយការណ៍នោះឡើយ។
- ការគ្រប់គ្រងបញ្ហាកូវីដ-១៩ប្រកបដោយនិរន្តរភាពមានសារៈសំខាន់ ជាពិសេសការផ្តោតកិច្ចខិតខំប្រឹងប្រែងអង្កេតតាមដានជំងឺដោយប្រើព័ត៌មានពហុប្រភពឡើងវិញ រួមទាំងយុទ្ធសាស្រ្តធ្វើតេស្តដើម្បីរកករណីឆ្លងបានឆាប់រហ័ស និងតាមដានការរីករាលដាល បង្កើនការត្រួតពិនិត្យការងារគ្រប់គ្រងការបង្ការការចម្លងរោគនៅតាមមូលដ្ឋានសុខាភិបាល។ វាសំខាន់ដែលត្រូវមានយុទ្ធសាស្រ្តនៅថ្នាក់ក្រោមជាតិដែលកំណត់ថាតើវិធានការសុខភាពសាធារណៈ និងសង្គមអ្វីខ្លះ និងពេលណាដែលប្រហែលជាត្រូវការដាក់ចេញបន្ថែម ក៏ដូចជាបន្តកិច្ចខិតខំប្រឹងប្រែងក្នុងការចាក់វ៉ាក់សាំងដោយផ្តោតទៅលើក្រុមប្រជាជនដែលមានហានិភ័យខ្ពស់ក្នុងការឆ្លង និងមានជំងឺធ្ងន់ធ្ងរ។ ការតាមដាន ខ្សែបន្ទាត់ក្រហមនៅតាមមន្ទីរ នៅតែមានសារៈសំខាន់ក្នុងអំឡុងពេលដែលមានការកើនឡើងនូវករណីឆ្លងនេះ។



**បដិសេធការទទួលខុសត្រូវ:** របាយការណ៍នេះមានព័ត៌មាន និងទិន្នន័យដែលត្រឹមត្រូវល្អក្នុងកំឡុងពេលផ្សព្វផ្សាយប៉ុណ្ណោះ។ ដោយសារការរាតត្បាតនៃជំងឺកូវីដ-១៩ ជាស្ថានការណ៍វិវឌ្ឍន៍ជាប្រចាំ ព័ត៌មាននៅក្នុងឯកសារនេះ អាចនឹងខុសទៅនឹងព័ត៌មានថ្មីៗ។

## អេពីដេមីសាស្ត្រ

**ក្រាហ្វិកទី១. ខ្សែកោងអេពីដេមិកនៃករណីជំងឺកូវីដ-១៩ បញ្ជាក់ដោយមន្ទីរពិសោធន៍ បែងចែកតាមកាលបរិច្ឆេទនៃរបាយការណ៍ឆ្នាំ ២០២១-២០២២ ***




*ចាប់ពីថ្ងៃ ៣០ ខែកញ្ញាឆ្នាំ២០២១មក មានតែលទ្ធផលតេស្តវីរុសកូវីដ-១៩ បញ្ជាក់ដោយ PCR ប៉ុណ្ណោះដែលត្រូវបានរាយការណ៍ជាចំនួនករណីឆ្លងផ្លូវការ។ ការតម្រូវធ្វើតេស្តសម្រាប់អ្នកដំណើរដែលចូលមកកម្ពុជាត្រូវបានលុបចោលចាប់តាំងពីថ្ងៃទី ១៧ ខែមីនា ឆ្នាំ ២០២២។

**តារាងទី១. យុទ្ធនាការចាក់វ៉ាក់សាំងកូវីដ-១៩តាមក្រុមគោលដៅ (បុគ្គលិកសុខាភិបាល មនុស្សចាស់ មនុស្សពេញ វ័យ និងកុមារ) *ទិន្នន័យគិតត្រឹមថ្ងៃទី ១៩ ខែសីហា ឆ្នាំ២០២២**

| | ប្រជាជនសរុប | មនុស្សពេញវ័យ | | យុវវ័យ | កុមារ | | |
|---|---|---|---|---|---|---|---|
| | | អាយុចាប់ពី ៦០ឆ្នាំ | អាយុចាប់ពី ១៨ឆ្នាំ | អាយុ១២-១៧ឆ្នាំ | អាយុ៦-១១ ឆ្នាំ | អាយុ៥ឆ្នាំ | អាយុ៣-៤ឆ្នាំ |
| | (N=16,000,000) | (N=1,378,688) | (N=10,000,000) | (N=1,827,348) | (N=1,897,382) | (N=304,317) | (N=610,730) |
| ចាប់ផ្តើម | 10 កុម្ភៈ 2021 | 10 កុម្ភៈ 2021 | 10 កុម្ភៈ:2021 | 1 សីហា 2021 | 17 កញ្ញា 2021 | 1 វិច្ឆិកា 2021 | 22 កុម្ភៈ 2022 |
| ដូសទី១ | 15,156,290 (94.7%) | 1,411,594 (103.4%) | 10,352,691 (103.5%) | 1,844, 284 (100.9%) | 2,084,561 (109.9%) | 419,591 (137.9%) | 455,163 (74.5%) |
| ដូសទី២ | 14,487,501 (90.5%) | 1,395,915 (101.2%) | 10,008,090 (100.1%) | 1,788,650 (97.9%) | 2,050,225 (108.1%) | 361,177 (118.7%) | 279,359 (45.7%) |
| ដូសទី៣ | 9,940,338 (62.1%) | 986,646 (71.6%) | 6,747,821 (67.5%) | 1,566,533 (85.7%) | 1,495,091 (78.8%) | 101,933 (33.5%) | 28,960 (4.7%) |
| ដូសទី៤ | 3,857,707 (24.1%) | 277,834 (20.2%) | 2,836,167 (28.4%) | 642,535 (35.2%) | 356,428 (18.8%) | 22,577 (7.4%) | N/A |
| ដូសទី៥ | 574,479 (3.6%) | 537,562 (5.4%) | | 36,917 (2.0%) | N/A | N/A | N/A |

**N/A: មិនអាចអនុវត្តបាន**



**បដិសេធការទទួលខុសត្រូវ:** របាយការណ៍នេះមានព័ត៌មាន និងទិន្នន័យដែលត្រឹមត្រូវល្អក្នុងកំឡុងពេលផ្សព្វផ្សាយប៉ុណ្ណោះ។ ដោយសារការរាតត្បាតនៃជំងឺកូវីដ-១៩ ជាស្ថានការណ៍វិវឌ្ឍន៍ជាប្រចាំ ព័ត៌មាននៅក្នុងឯកសារនេះ អាចនឹងខុសទៅនឹងព័ត៌មានថ្មីៗ។

**តារាងទី2. អត្រានៃហេតុការណ៍កើតមានក្រោយពេលចាក់វ៉ាក់សាំង (AEFI) ក្នុងចំណោម ១០០.០០០ដូស តាមប្រភេទវ៉ាក់សាំងកូវីដ-១៩។ *ទិន្នន័យគិតត្រឹមថ្ងៃទី ១៩ ខែសីហា ឆ្នាំ២០២២**

| ប្រភេទវ៉ាក់សាំងកូវីដ-១៩ | **Sinovac** | Sinopharm | AstraZeneca (Covishield) | **Janssen** (Ad26.COV2-S) | **AstraZeneca** (Vaxzevria) | **Moderna** (Spikevax) | **Pfizer** BioNTech (Comirnary) | **សរុប** |
|---|---|---|---|---|---|---|---|---|
| ចំនួនករណី | 101 | 79 | 29 | 4 | 23 | 3 | 1 | **240** |
| ចំនួនដូសសរុបបានចាក់ | 25,425,892 | 7,507,947 | 354,111 | 1,053,151 | 4,158,876 | 352,638 | 2,731,418 | **41,584,033** |
| អត្រានៃហេតុការណ៍ក្នុងចំណោម ១០០.០០០ដូស | **0.40** | **1.05** | **8.19** | **0.38** | **0.55** | **0.85** | **0.04** | **0.58** |

## វិធានការសុខភាពសាធារណៈ និងសង្គម

- ការពាក់ម៉ាសនៅតែជាកាតព្វកិច្ចនៅពេលបិតនៅកន្លែងខាងក្នុង និងបិទជិតដូចជាបន្ទប់ប្រជុំ និងរោងភាពយន្ត។
- មិនមានការផ្លាស់ប្តូរចំពោះវិធានការសុខភាពសាធារណៈ និងវិធានការសង្គមនោះទេកាលពីខែមុននេះ។

## ឯកសារយើង និងតំណរភ្ជាប់ដែលពាក់ព័ន្ធ

- គេហទំព័រក្រសួងសុខាភិបាល: គេហទំព័រផ្លូវការរបស់ក្រសួងសុខាភិបាល
- របាយការណ៍ស្តីពីស្ថានភាពជំងឺកូវីដ-១៩ដោយក្រសួងសុខាភិបាល និងអង្គការសុខភាពពិភពលោក: របាយការណ៍ស្តីពីស្ថានភាពជំងឺកូវីដ-១៩ចុងក្រោយបំផុតសម្រាប់ប្រទេសកម្ពុជា។
- របាយការណ៍ស្តីពីស្ថានភាពថ្នាក់តំបន់:របាយការណ៍ស្តីពីស្ថានភាពជំងឺកូវីដ-១៩ចុងក្រោយបំផុតសម្រាប់អង្គការសុខភាពពិភពលោកតំបន់ប៉ាស៊ីហ្វិកខាងលិច។
- របាយការណ៍ស្តីពីស្ថានភាពថ្នាក់សាកល: របាយការណ៍បច្ចុប្បន្នភាពស្តីពីកូវីដ-១៩ផ្នែកប្រតិបត្តិការ និងអេពីដេមីសាស្ត្ររបស់អង្គការសុខភាពពិភពលោកថ្នាក់សាកល។
- គោលការណែនាំរបស់អង្គការសុខភាពពិភពលោក: គោលការណែនាំសម្រាប់ប្រទេស និងបច្ចេកទេសអំពីកូវីដ-១៩ចុងក្រោយបំផុតរបស់អង្គការសុខភាពពិភពលោក។
- ក្តារព័ត៌មានឌីជីថលស្តីពីកូវីដ-១៩របស់អង្គការសុខភាពពិភពលោក: ទិន្នន័យកូវីដ-១៩កម្រិតតំបន់ និងពិភពលោកចុងក្រោយបំផុត។



**បដិសេធការទទួលខុសត្រូវ:** របាយការណ៍នេះមានព័ត៌មាន និងទិន្ន័យដែលត្រឹមត្រូវល្អក្នុងកំឡុងពេលផ្សព្វផ្សាយប៉ុណ្ណោះ។ ដោយសារការរាតត្បាតនៃជំងឺកូវីដ-១៩ ជាស្ថានការណ៍វិវឌ្ឍន៍ជាប្រចាំ ព័ត៌មាននៅក្នុងឯកសារនេះ អាចនឹងខុសទៅនឹងព័ត៌មានថ្មីៗ។